ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ : ០០៥ គ.ជ.ប

ថ្ងៃអាទិត្យ ១៣កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណើរការជ្រើសរើសសមាសភាព គធ.ខប ទាំង ២៥ រាជធានី ខេត្ត

កាលពីថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០២២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចលើលទ្ធផលនៃការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ទាំង ២៥ ដែលមានចំនួនសរុប ១៧៥ រូប បានប្រឡងជាប់។

សមាសភាពដែលប្រឡងជាប់សម្រាប់រាជធានី ខេត្តនីមួយៗមានចំនួន ៧ រូប ដោយឆ្លងកាត់វិញ្ញាសារប្រឡងសំណួរសរសេរ-QCM និងសម្ភាសន៍ចំណេះដឹងទូទៅទាក់ទងនឹងការបោះឆ្នោត ហើយដែលមានមុខតំណែង ៖

១- ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
២- អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
៣- សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល
៤- សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ
៥- សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស
៦- សមាជិកទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត
៧- សមាជិកទទួលបន្ទុកផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ។

ក្នុងការប្រឡងជ្រើសរើសនេះ មានមន្ត្រីរាជការ គ.ជ.ប ដែលបម្រើការងារនៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) មួយចំនួន បានដាក់ពាក្យប្រឡង ហើយបានជាប់ជាប្រធាន ឬជាអនុប្រធាន ឬជាសមាជិកនៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ដែលជាហេតុធ្វើឱ្យកន្លែងមន្ត្រីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត មួយចំនួននៅទំនេរ។

អនុលោមតាមស្មារតីមាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប សម្រេចតែងតាំងប្រធាន និងអនុប្រធានលេខាធិការដ្ឋាននៃ



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) ដោយប្រគល់ភារកិច្ចជូនអគ្គលេខាធិការ គ.ជ.ប ក្នុងការរៀបចំសមាសភាពនេះ។ ក្នុងដំណើរការរៀបចំសមាសភាពខាងលើ អគ្គលេខាធិការ គ.ជ.ប ត្រូវផ្តល់អាទិភាពចំពោះប្រធានផ្នែកនៃ លធ.ខប ដែលមិនបានជាប់ក្នុងសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ឬក្នុងករណីចាំបាច់ អគ្គលេខាធិការ គ.ជ.ប អាចពិនិត្យមើលសមាសភាពក្នុងចំណោមបេក្ខជនប្រឡងមុខតំណែងប្រធាន ឬអនុប្រធាន ឬសមាជិកណា ដែលមានគុណសម្បត្តិ លក្ខណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារក្នុងមុខតំណែងទំនេរនេះ។

សមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ទាំង ១៧៥រូប នឹងត្រូវបំពេញភារកិច្ចចាប់ពីថ្ងៃអង្គារ ទី១ ខែកុម្ភៈ ឆ្នាំ២០២២ រហូតដល់ថ្ងៃព្រហស្បតិ៍ ទី៣០ ខែមិថុនា ឆ្នាំ២០២២ សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh